00712746

E108

ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 07 / 2011
ម៉ោង (Time/Heure): 9:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

អនុស្សរណៈ: - អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ជូនចំពោះ: ភាគីទាំងអស់នៃសំណុំរឿង ០០២

កាលបរិច្ឆេទ: ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១

ពី: ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន: លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

កម្មវត្ថុ: សេចក្តីណែនាំដល់ភាគី (មុនពេលមានការពិភាក្សានៅក្នុងកិច្ចសវនាការបឋមស្តីពីបញ្ជីបណ្តោះអាសន្នឈ្មោះសាក្សី, អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី)

អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់បំភ្លឺលើបញ្ហាមួយចំនួនដែលបានកើតមានកាលពីថ្ងៃដំបូងនៃសវនាការបឋម នៅមុនពេលធ្វើការពិភាក្សាអំពីបញ្ជីបណ្តោះអាសន្នឈ្មោះសាក្សី, អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់អង្គហេតុដែលត្រូវជំនុំជម្រះនៅដំណាក់កាលដំបូងនេះ។ តាមការគ្រោងទុកការពិភាក្សានេះនឹងត្រូវធ្វើនៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១។

១. បញ្ជីបណ្តោះអាសន្នឈ្មោះសាក្សី, អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអង្គជំនុំជម្រះសាលាដំបូងប្រគល់ឱ្យភាគីដោយសម្ងាត់។ ភាគីមិនត្រូវបង្ហើបឱ្យសាធារណជន ឬសារព័ត៌មាន បានដឹងអំពីខ្លឹមសារនៃបញ្ជីនេះឡើយ។

២. ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងយល់ព្រមធ្វើការពិភាក្សាទៅលើបញ្ហាបញ្ជីបណ្តោះអាសន្នឈ្មោះសាក្សីនេះជាសាធារណៈក្នុងអំឡុងថ្ងៃចុងក្រោយនៃសវនាការបឋម ភាគីត្រូវប្រើរហស្សនាមរបស់សាក្សីដែលអង្គជំនុំជម្រះបានដាក់ឱ្យនៅក្នុងបញ្ជីបណ្តោះអាសន្ន។ ប្រសិនបើភាគីមិនឯកភាពទៅនឹងចំណុចនេះ ខ្លួនគួរគប្បីជូនដំណឹងទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ពោលគឺឱ្យបានមុនថ្ងៃចុងក្រោយនៃសវនាការបឋម ដោយមានរៀបរាប់អំពីមូលដ្ឋាននៃការជំទាស់។

៣. ឈ្មោះទាំងប៉ុន្មានដែលមានក្នុងបញ្ជីបណ្តោះអាសន្ននេះ ត្រូវបានរៀបចំទៅតាមលំដាប់តួអក្សរាវិរុទ្ធភាសាអង់គ្លេស។ នៅដំណាក់កាលនេះ អង្គជំនុំជម្រះនៅពុំទាន់ចេញសេចក្តីសម្រេចណាមួយស្តីពីលំដាប់លំដោយនៃការធ្វើសក្ខីកម្មនៅឡើយទេ។

៤. អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថានៅដំណាក់កាលដំបូងនៃការជំនុំជម្រះនេះ ខ្លួននឹងពិនិត្យមើលគោលនយោបាយដែលរបបកម្ពុជាប្រជាធិបតេយ្យបានប្រកាន់យក, ការអភិវឌ្ឍន៍គោលនយោបាយទាំងនេះ និងអ្នកស្ថិតក្នុងចំណោមជនជាប់ចោទដែលអាចបានចូលរួមក្នុងការអភិវឌ្ឍន៍គោលនយោបាយទាំងនេះ ឬបានដឹងអំពីគោលនយោបាយទាំងនេះ។ សម្រាប់ដំណាក់កាលនេះ អង្គជំនុំជម្រះមិនទាន់ពិនិត្យមើលការអនុវត្តគោលនយោបាយទាំងនេះនៅឡើយទេ។

៥. អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតតាមសំណើរបស់សហមេធាវីនាំមុខ ដែលបានស្នើសុំពន្យារពេលកំណត់នៃការដាក់បញ្ជីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីបន្ថែម ដោយអំណាចនៃសាលដីកាសម្រេចទទួលយកដើមបណ្ដឹងរដ្ឋប្បវេណីរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១។ អង្គជំនុំជម្រះទុកពេលវេលាឲ្យសហមេធាវីនាំមុខរហូតដល់ថ្ងៃ ព្រហស្បត្តិ៍ ទី ២៨ ខែ កក្កដា ឆ្នាំ ២០១១ ដើម្បីបញ្ជាក់ថាតើដើមបណ្ដឹងរដ្ឋប្បវេណីណាខ្លះដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់កាលពីថ្ងៃទី ២៤ មិថុនា ឆ្នាំ ២០១១ អាចពាក់ព័ន្ធនឹងបញ្ហាអង្គហេតុដែលត្រូវសម្រេចក្នុងអំឡុងដំណាក់កាលដំបូងនៃការជំនុំជម្រះនេះ។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានពេលរហូតដល់ថ្ងៃ ច័ន្ទ ទី ២៩ ខែ សីហា ឆ្នាំ ២០១១ ដើម្បីបញ្ជាក់ថាតើដើមបណ្ដឹងរដ្ឋប្បវេណីណាខ្លះដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ អាចពាក់ព័ន្ធនឹងដំណាក់កាលបន្ទាប់នៃការជំនុំជម្រះ។ ដើម្បីធានាថាការជំនុំជម្រះនឹងប្រព្រឹត្តទៅបានដោយឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូងនឹងចេញសេចក្ដីសម្រេចមួយ ពាក់ព័ន្ធនឹងបញ្ហាថាតើដើមបណ្ដឹងរដ្ឋប្បវេណីណាខ្លះដែលនឹងត្រូវអង្គជំនុំជម្រះស្ដាប់សក្ខីកម្មនៅសវនាការ។